# វគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិនៃព្រះគម្ពីរមរមន ៖ ការវាយតម្លៃ ទី ១

**នីហ្វៃទី១ ៣:៧ រហូតដល់ ម៉ូសាយ ១៨:៨–១០**

## សេចក្តីយោងចំណេះចំណានខាងគោលលទ្ធិ

សម្រាប់សំណួរទី ១–៣ សូមសរសេរអក្សរនៃសេចក្តីយោងដែលត្រូវគ្នាក្នុងចន្លោះទទេនៅជាប់នឹងឃ្លានីមួយៗ ។ សូមកុំប្រើព្រះគម្ពីររបស់អ្នកដើម្បីធ្វើការវាយតម្លៃនៅផ្នែកនេះឡើយ ។

| ឃ្លាគន្លឹះ | សេចក្តីយោងបទគម្ពីរ |
|---|---|
| ______ ១. « អស់អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ . . . បានពរគ្រប់យ៉ាង » ។ | a. នីហ្វៃទី១ ៣:៧ |
| | b. នីហ្វៃទី២ ២:២៥ |
| ______ ២. « ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗដែលព្រះអម្ចាស់ទ្រង់បានបញ្ជា » ។ | c. នីហ្វៃទី២ ២:២៧ |
| | d. ម៉ូសាយ ២:៤១ |
| ______ ៣. « លោកអ័ដាមបានធ្លាក់ខ្លួន ដើម្បីឲ្យមានមនុស្សលោក ហើយមានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្តីអំណរ » ។ | e. ម៉ូសាយ ៣:១៩ |

## ឃ្លាបទគម្ពីរគន្លឹះ

សម្រាប់សំណួរទី ៤–៦ សូមបំពេញពាក្យដែលបាត់ក្នុងឃ្លាបទគម្ពីរគន្លឹះនៃចំណេះចំណានខាងគោលលទ្ធិនេះ ។ សូមកុំប្រើព្រះគម្ពីររបស់អ្នកដើម្បីធ្វើការវាយតម្លៃនៅផ្នែកនេះឡើយ ។

៤. « កាលណាអ្នករាល់គ្នានៅក្នុង _______________ ដល់មនុស្សទូទៅ _______________ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ _______________ របស់អ្នកតែប៉ុណ្ណោះ » ( ម៉ូសាយ ២:១៧) ។

៥. « [ សម្រាត ] ភាព _______________ ខាងសាច់ឈាមចេញ ហើយ [ ក្លាយទៅជា ] _______________ តាមរយៈ _______________ នៃព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » ( ម៉ូសាយ ៣:១៩ ) ។

៦. ត្រូវ « _______________ ដោយនូវព្រះនាមនៃព្រះអម្ចាស់ ដើម្បីធ្វើជា _______________ . . . ថា អ្នករាល់គ្នាបានចូលក្នុង _______________ ជាមួយនឹងទ្រង់ » ( ម៉ូសាយ ១៨:៨–១០ ) ។

## ការអនុវត្តចំពោះស្ថានភាពជីវិតជាក់ស្តែង

អ្នកអាចប្រើប្រាស់ព្រះគម្ពីររបស់អ្នកសម្រាប់ការវាយតម្លៃដែលនៅសល់ ។

សម្រាប់សំណួរ ៧–៨ សូមរកមើលនូវវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិមួយ ឬ ច្រើន ដែលអាចជួយដល់នរណាម្នាក់ស្ថិតនៅក្នុងស្ថានភាពខាងក្រោម និងពន្យល់អំពីរបៀបដែលសេចក្តីពិតនៅក្នុងវគ្គបទគម្ពីរអាចជួយបាន ។ បន្ទាប់មក សូមអនុវត្តតាមការណែនាំសម្រាប់សំណួរ ៩ ។

៧. យុវជនម្នាក់ត្រូវធ្វើការសម្រេចចិត្តដ៏សំខាន់មួយ ដែលអាចនឹងមានឥទ្ធិពលខ្លាំងដល់អនាគតរបស់គាត់ ។ គាត់មានការភ័យខ្លាច ហើយមិនដឹងច្បាស់ថា ត្រូវជ្រើសរើសអ្វីនោះទេ ។

______________________________________________

______________________________________________

៨. យុវនារីម្នាក់រស់នៅក្នុងស្ថានភាពមួយ ដែលនាងគិតថា នាងពិបាកធ្វើតាមព្រះបញ្ញត្តិរបស់ព្រះយ៉ាងខ្លាំង ។ នាងចង់ស្តាប់តាមបង្គាប់ព្រះ ប៉ុន្តែចំពោះស្ថានភាពរបស់នាងហាក់បីដូចជាពិបាកខ្លាំងពេក ។

______________________________________________

______________________________________________

៩. សូមជ្រើសរើសវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិទាំង ១២ ចេញពី នីហ្វៃទី ១ ហូតដល់ម៉ូសាយ ហើយចែកចាយអំពីស្ថានភាពមួយ ដែលសេចក្ដីពិតបានបង្រៀននៅក្នុងវគ្គបទគម្ពីរនោះអាចជួយដល់ក្មេងជំទង់ម្នាក់ក្នុងជីវិតរបស់គាត់ ។

## គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ

សម្រាប់សំណួរ ១០–១១ សូមបង្ហាញចំណេះដឹងរបស់អ្នកអំពីសមត្ថភាពក្នុងការប្រើប្រាស់គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ ។

១០. សូមពន្យល់ដោយសង្ខេបអំពីគោលការណ៍ទាំងបីខាងក្រោមអំពីការទទួលបានចំណេះដឹងខាងវិញ្ញាណតាមពាក្យសម្ដីរបស់អ្នកផ្ទាល់ ។

a. ធ្វើសកម្មភាពដោយសេចក្ដីជំនឿ ។

b. ពិនិត្យមើលគោលគំនិត និងសំណួរទាំងឡាយដោយការប្រើទស្សនដ៏អស់កល្បមួយ ។

c. ស្វែងរកការយល់ដឹងបន្ថែមតាមរយៈប្រភពដែលបានតែងតាំងដ៏ទេវភាព ។

១១. មានមិត្តភក្តិម្នាក់កំពុងសួរសំណួរថា មូលហេតុអ្វីបានជាមានចំណុចខ្លះដែលនាងទើបនឹងរៀននៅសាលាហាក់ដូចជាផ្ទុយនឹងអ្វី ដែលព្រះបានបង្រៀនតាមរយៈបទគម្ពីរ និងព្យាការីសម័យទំនើប ។ សូមឆ្លើយសំណួរខាងក្រោមនេះ ៖

a. តើនាងអាចធ្វើកិច្ចការជាក់លាក់អ្វីខ្លះ ដើម្បីធ្វើសកម្មភាពដោយសេចក្ដីជំនឿបាន ?

b. តើការមើលឃើញស្ថានភាពនេះចេញពីទស្សនដ៏អស់កល្បមួយអាចជួយនាងយ៉ាងដូចម្ដេច ?

c. វគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិគឺជាឧទាហរណ៍នៃប្រភពដែលបានតែងតាំងដ៏ទេវភាព ។ តើវគ្គចំណេះចំណានខាងគោលលទ្ធិអ្វីខ្លះចាប់ពីនីហ្វៃទី ១ ហូតដល់ម៉ូសាយ អាចជួយដល់មិត្តរបស់អ្នកបាន ? តាមវិធីណា ?

### មានឥទ្ធិពលលើជីវិតរបស់អ្នក

១២. តើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិដែលអ្នកបានសិក្សាក្នុងឆមាសនេះមានឥទ្ធិពលអ្វីលើអ្នក ? តើវាមានឥទ្ធិពលលើអ្នកយ៉ាងដូចម្ដេច ? តើវគ្គបទគម្ពីរនេះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved. PD60013873_258_522-teacher_handout-1